# ការលត់ដំខ្លួនផ្នែកសីលធម៌

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន
ក្រុមនៃពួកសាវកដប់ពីរនាក់

*ការលត់ដំខាងសីលធម៌ គឺជាការអនុវត្តន៍សិទ្ធិជ្រើសរើសត្រូវដ៏ខ្ជាប់ខ្ជួន ពីព្រោះវាគឺជារឿងត្រឹមត្រូវ ទោះជាវាជារឿងលំបាកក្តី ។*

អំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ប្រធាន ដែមស៍ អ៊ី ហ្វោស្ត ដែលជាយុវជនម្នាក់ដែលបានចូលរួមនៅក្នុងកងទ័ពរបស់សហរដ្ឋអាមេរិកនៅពេលនោះ បានដាក់ពាក្យចូលរៀននៅ សាលាបំពាក់បំប៉ននាយទាហាន ។ លោកបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាត្រួតពិនិត្យ ជាអ្នកដែលលោកបានពិពណ៌នាថាជា "អ្នកមានរបរទាហានដ៏តឹងរឹង" នោះ ។ មួយរយៈពេលក្រោយមក សំណួររបស់ពួកគេបានងាកទៅរកបញ្ហាសាសនាវិញ ។ សំរាប់សំណួរចុងក្រោយ គឺបានសួរបែបនេះថា ៖

"'តើវាជាការត្រឹមត្រូវដែរឬទេ ដែលក្រមច្បាប់សីលធម៌គួរតែមានការបន្ធូរបន្ថយនៅក្នុងសង្គ្រាមនោះ? តើវាជាការត្រឹមត្រូវទេ ដែលការដាក់ទម្ងន់នៅក្នុងសង្គ្រាម បានលើកលែងទោសដល់មនុស្សនៅក្នុងការធ្វើកិច្ចការដែលពួកគេនឹងមិនធ្វើនៅឯគេហដ្ឋានក្នុងស្ថានភាពធម្មតានោះ?

ប្រធាន ហ្វោស្ត បានលើកឡើងថា ៖ "ខ្ញុំបានដឹងថា ពេលនេះប្រហែលជាឱកាសមួយដើម្បីធ្វើឱ្យពួកគេមានការភ្ញាក់ផ្អើល ហើយមើលឃើញថា ខ្ញុំជាមនុស្សដែលមានគំនិតទូលំទូលាយ ។ ខ្ញុំបានដឹងយ៉ាងច្បាស់ថា ពួកបុរសដែលកំពុងចោទសួរសំណួរដល់ខ្ញុំ មិនបានរស់នៅតាម បទដ្ឋានដែលខ្ញុំត្រូវបានបង្រៀនឡើយ ។ មានគំនិតមួយបានផុសឡើងនៅក្នុងគំនិតរបស់ខ្ញុំថា ខ្ញុំប្រហែលជាអាចនិយាយថា ខ្ញុំមានជំនឿផ្ទាល់ខ្លួនរបស់ខ្ញុំ ប៉ុន្តែមិនចង់បំពានដល់អ្នកដទៃឡើយ ។ ប៉ុន្តែ នៅក្នុងគំនិតរបស់ខ្ញុំហាក់ដូចជាផុសឡើងនូវទឹកមុខមនុស្សដែលខ្ញុំបានបង្រៀនអំពីច្បាប់ព្រហ្មចារីភាព កាលពីនៅជាអ្នកផ្សព្វផ្សាយសាសនា ។ នៅទីបំផុត ខ្ញុំក៏បានឆ្លើយដោយសាមញ្ញថា 'ខ្ញុំមិនជឿថា មានបទដ្ឋានសីលធម៌ពីរយ៉ាងនោះទេ' ។

"ខ្ញុំបានចេញទៅដោយមានការខកចិត្តជាខ្លាំង ដោយសារថា [ពួកគេ] មិនបានចូលចិត្តនឹងចម្លើយរបស់ខ្ញុំឡើយ... ហើយពួកគេនឹងផ្តល់ពិន្ទុឱ្យខ្ញុំយ៉ាងទាបបំផុត ។ ប៉ុន្មានថ្ងៃក្រោយមក នៅពេលចេញលទ្ធផល នោះខ្ញុំបានប្រលងជាប់ ទាំងភ្ញាក់ផ្អើល ។ ខ្ញុំមានឈ្មោះនៅក្នុងក្រុមទីមួយដែលត្រូវចូលសាលាបំពាក់បំប៉ននាយទាហាន!..."

"ការសំរេចចិត្តនេះគឺជាការសំរេចចិត្តដ៏សំខាន់មួយនៅក្នុងជីវិតរបស់ខ្ញុំ" ។1

ប្រធាន ហ្វោស្ត បានដឹងថា យើងទាំងអស់គ្នាមាននូវអំណោយទាននៃសិទ្ធិជ្រើសរើសខាងសីលធម៌ដែលព្រះប្រទានឱ្យ---ជាសិទ្ធិដើម្បីធ្វើការជ្រើសរើស និងជាកាតព្វកិច្ចដើម្បីទទួលខុសត្រូវចំពោះការជ្រើសរើសទាំងនោះ (សូមមើល គ. និង ស. 101:78) ។ លោកក៏បានយល់ដឹង និងបានបង្ហាញផងដែរថា ដើម្បីសំរេចបាននូវលទ្ធផលវិជ្ជមាន នោះសិទ្ធិជ្រើស រើសខាង សីលធម៌ត្រូវមានការរួមផ្សំដោយការលត់ដំខ្លួនផ្នែកសីលធម៌ផងដែរ ។

ពាក្យ "ការលត់ដំខ្លួនផ្អែកសីលធម៌" គឺខ្ញុំចង់មានន័យថា ជាការលត់ដំខ្លួនដែលពឹងផ្អែកទៅលើបទដ្ឋានសីលធម៌។ ការលត់ដំខ្លួនផ្អែកសីលធម៌ គឺជាការអនុវត្តន៍សិទ្ធិជ្រើសរើសយ៉ាងខ្ជាប់ខ្ជួនចំពោះរឿងត្រឹមត្រូវ ពីព្រោះវាគឺជាការត្រឹមត្រូវ ទោះបីជាស្ថិតនៅក្នុងគ្រាលំបាកក្តី។ វាបដិសេធចំពោះជីវិតដែលផ្តោតសំខាន់តែលើខ្លួនឯង ដើម្បីអភិវឌ្ឍដល់អាកប្បកិរិយាដ៏ប្រពៃ នៃការគោរព និងភាពឆ្អើមដ៏ពិតតាមរយៈការបំរើដូចជាព្រះគ្រីស្ទ (សូមមើល ម៉ាកុស 10:42--45)។ ជាភាសាអង់គ្លេស ឫសនៃពាក្យ "ការលត់ដំខ្លួន" គឺដូចគ្នានឹងឫសនៃពាក្យ "សិស្ស" ដោយបានណែនាំនូវ ការពិតមួយដល់គំនិតថា ដំណើរស្របគ្នាទៅនឹងគំរូ និងការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ គឺជា *ការលត់ដំខ្លួន* ដ៏ឧត្តម ដែលធ្វើឱ្យបុគ្គលគ្រប់រូបមានគុណធម៌ និងមានសីលធម៌ដ៏ប្រពៃ ដោយរួមផ្សំនឹងព្រះគុណរបស់ទ្រង់។

ការលត់ដំខ្លួនផ្អែកសីលធម៌របស់ព្រះយេស៊ូវ ត្រូវបានចាក់ឫសនៅក្នុងភាពជាសិស្សរបស់ទ្រង់ចំពោះព្រះវរបិតា។ ទ្រង់បានពន្យល់ទៅកាន់ពួកសិស្សរបស់ទ្រង់ថា "អាហារខ្ញុំគឺត្រង់ដែលខ្ញុំធ្វើតាមព្រះហឫទ័យនៃព្រះ ដែលចាត់ឱ្យខ្ញុំមក ព្រមទាំងបង្ហើយការរបស់ទ្រង់នោះឯង" (យ៉ូហាន 4:34)។ តាមលំនាំដូចគ្នានេះ ការលត់ដំខ្លួនផ្អែកសីលធម៌របស់យើង ត្រូវបានចាក់ឫសនៅក្នុងភក្តីភាព និងការលះបង់ចំពោះព្រះវរបិតា និងព្រះរាជបុត្រា។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនេះ ហើយដែលផ្តល់នូវភាពជឿជាក់ខាងសីលធម៌ ហើយនឹងជាពំនាក់នៃការលត់ដំខ្លួនផ្អែកសីលធម៌។

សង្គមភាគច្រើនដែលយើងរស់នៅបានបរាជ័យនៅក្នុងការលើកដំកើងដល់ការលត់ដំខ្លួនផ្អែកសីលធម៌។ សង្គមទាំងនោះបង្រៀនថា សេចក្តីពិតមានភាពប្រែប្រួល ហើយថាមនុស្សគ្រប់រូបអាចសំរេចចិត្តចំពោះអ្វី ដែលត្រឹមត្រូវដោយខ្លួនឯងបាន។ គោលគំនិតទាំងឡាយ មានដូចជាអំពើបាប និងអំពើខុសឆ្គង គឺត្រូវបានផ្តន្ទាទោស ស្របទៅតាម "ការវិនិច្ឆ័យលើគុណតម្លៃ"។ ដូចដែលព្រះអម្ចាស់បានរៀបរាប់ពីការណ៍នេះថា "មនុស្សគ្រប់រូបដើរតាម ផ្លូវរបស់ខ្លួនគេផ្ទាល់ ហើយតាមរូបភាពនៃព្រះរបស់ខ្លួនគេផ្ទាល់" (គ. និង ស. 1:16)។

ជាលទ្ធផល ការលត់ដំខ្លួនមានការសឹករិចរិល ហើយសង្គមត្រូវបានទុកចោលដើម្បីព្យាយាមថែរក្សារបៀបរៀបរយ និងការគោរពដោយការបង្ខិតបង្ខំ។ ការខ្វះភាពគ្រប់គ្រងទៅលើគំនិតរបស់បុគ្គលបានធ្វើឱ្យរដ្ឋាភិបាលត្រូវគ្រប់គ្រងផ្នែកខាងក្រៅវិញ។ មានអ្នកសរសេរសារព័ត៌មានម្នាក់បានសង្កេតឃើញថា "[ជាឧទាហរណ៍] ឥរិយាបថដ៏សុភាពរាបសា [ធ្លាប់] បានការពារដល់ស្ត្រីឱ្យរួចផុតពីអាកប្បកិរិយាដ៏ថោកទាប...។

សព្វថ្ងៃនេះ យើងបានពឹង ផ្អែកទៅលើច្បាប់រំលោភបំពានខាងផ្លូវភេទ ដើម្បីទប់ស្កាត់ដល់អាកប្បកិរិយាដ៏ថោកទាបទាំងឡាយ...។ មន្ត្រីនគរបាល និងច្បាប់ទាំងឡាយមិនអាចជំនួសឱ្យប្រពៃណី ទំនៀមទម្លាប់ និងគុណតម្លៃខាងសីលធម៌ ជាមធ្យោបាយមួយសំរាប់កែប្រែដល់អាកប្បកិរិយារបស់មនុស្សបាននោះឡើយ។ យ៉ាងច្រើនបំផុតនោះគឺថា ក្រុមនគរបាល និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺជាខ្សែបន្ទាត់ការពារដ៏អស់សង្ឃឹមចុងក្រោយគេបង្អស់ សំរាប់សង្គមដែលមាន អារ្យធម៌ដ៏ខ្ពង់ខ្ពស់មួយតែប៉ុណ្ណោះ។

ការកើនឡើងនូវទំនុកចិត្តរបស់យើងចំពោះច្បាប់ទាំងឡាយ ដើម្បីផ្លាស់ប្តូរ អាកប្បកិរិយា គឺជារង្វាស់មួយស្តីអំពីរបៀបដែលយើងកំពុងក្លាយខ្លួនទៅជាមនុស្សគ្មានអារ្យធម៌"។[2]

យើងកំពុងជួបនឹងដំណើរសេដ្ឋកិច្ចធ្លាក់ចុះ នៅទីកន្លែងជាច្រើននៃពិភពលោកនេះ។ វាបានកើតឡើង ដោយបុព្វហេតុជាច្រើន ប៉ុន្តែបុព្វហេតុដ៏សំខាន់មួយ គឺជាការរីកសាយភាយនៃឥរិយាបថខ្វះភាពស្មោះត្រង់ និង អសីលធម៌ ជាពិសេសនៅក្នុងទីផ្សារអចលទ្រព្យ និងហិរញ្ញវត្ថុក្នុងសហរដ្ឋអាមេរិក។ ប្រតិកម្មជាច្រើនបានផ្តោត សំខាន់ទៅលើការអនុមតិច្បាប់ឱ្យបានច្រើន ហើយឱ្យបានម៉ឺងម៉ាត់។ ប្រហែលជាការណ៍នោះអាចរារាំងឥរិយាបថខុសឆ្គង នៃមនុស្សមួយចំនួន ប៉ុន្តែជាធម្មតា អ្នកផ្សេងទៀតនឹងច្នៃប្រឌិតកាន់តែច្រើនឡើងនៅក្នុងការជៀសវាងច្បាប់។ [3] ច្បាប់ដែលមានលក្ខណៈប៉ិនប្រសប់ទាំងឡាយនឹងមិនអាចមានល្មមគ្រប់គ្រាន់ដើម្បីស្មានទុកជាមុន និងគ្រប់គ្រងលើ ស្ថានភាពគ្រប់យ៉ាងបានឡើយ ទោះជាមានក្តី ក៏ការអនុវត្តន៍ច្បាប់នឹងក្លាយទៅជារឿងថ្លៃ ហើយស្មុគស្មាញផងដែរ។ ដំណើរនេះបានដឹកនាំទៅរកការកាត់បន្ថយសិទ្ធិសេរីភាពរបស់មនុស្សគ្រប់រូប---នៅក្នុងពាក្យមួយឃ្លាដែលមិន អាចបំភ្លេចបានរបស់ ប៊ីស្សព ហ្វូតុន ជេ ឆីន បានលើកឡើងថា "យើងមិនបានទទួលយកនឹមរបស់ព្រះគ្រីស្ទ ដូច្នេះឥឡូវនេះ យើងត្រូវភ័យញ័រនៅក្រោមនឹមរបស់សេសារវិញ"។4

នៅទីបំផុត គឺមានតែត្រីវិស័យខាងសីលធម៌នៅក្នុងខ្លួនរបស់បុគ្គលម្នាក់ៗប៉ុណ្ណោះ ដែលអាចប្រឈមមុខយ៉ាងមាន ប្រសិទ្ធភាពជាមួយនឹងឫសគល់បុព្វហេតុ និងរោគសញ្ញានានា នៃការពុករលួយនៅក្នុងសង្គមបាន។ សង្គមនានានឹងព្យាយាម បង្កើតច្បាប់ដោយឥតប្រយោជន៍ បើអំពើបាបមិនត្រូវបានប្រកាសជាឱឡារិកថាជាអំពើបាប ហើយការលត់ដំខ្លួនផ្នែកសីលធម៌ ពុំមាននៅក្នុងបញ្ជីគុណធម៌របស់ប្រជាពលរដ្ឋទេនោះ។[5]

ការលត់ដំខ្លួនផ្នែកសីលធម៌ត្រូវបង្រៀននៅឯគេហដ្ឋាន។ ខណៈដែលយើងមិនអាចគ្រប់គ្រងនូវអ្វីដែលអ្នកដទៃអាចធ្វើ ឬមិនអាចធ្វើ នោះពួកបរិសុទ្ធថ្ងៃចុងក្រោយអាចឈរយ៉ាងទៀងត្រង់ជាមួយនឹង ពួកអ្នកដែលបង្ហាញពីគុណធម៌នៅក្នុងជីវិតរស់នៅរបស់ពួកគេ ហើយបណ្តុះគុណធម៌នៅក្នុងគំនិតរបស់ជំនាន់កំពុងពេញវ័យ។ សូមចងចាំពីប្រវត្តិសាស្ត្រនៅ ក្នុងព្រះគម្ពីរមរមនស្តីអំពីយុវជនជាច្រើនរូបដែលបានក្លាយខ្លួនជាបុគ្គលដ៏សំខាន់ ដោយធ្វើឱ្យសាសន៍នីហ្វៃទទួលជ័យ ជំនះ នៅក្នុងសង្គ្រាម ដ៏យូរអង្វែងពីឆ្នាំ 66 ដល់ 60 មុន គ.ស.---គឺជាកូនប្រុសរបស់ប្រជាជនអាម៉ូន។ អាកប្បកិរិយា និងការលត់ដំខ្លួនរបស់ ពួកគេត្រូវបានរៀបរាប់នៅក្នុងពាក្យសម្តីទាំងនេះថា :

ពួកគេជាមនុស្សស្មោះត្រង់គ្រប់ពេលវេលា ទោះនៅក្នុងកិច្ចការណាក៏ដោយដែលពួកគេទទួលផ្ទុក។

"មែនហើយ ពួកគេគឺជាមនុស្សស្មោះត្រង់ ហើយម៉ឺងម៉ាត់ ព្រោះពួកគេត្រូវបានបង្ហាត់ឱ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយ នៃព្រះ ហើយឱ្យដើរដោយស្មោះត្រង់នៅចំពោះទ្រង់ (អាលម៉ា 53:20—21)។

“ឥឡូវនេះ ពួកគេមិនដែលធ្លាប់បានប្រយុទ្ធមកទេ តែគេពុំខ្លាចស្លាប់ឡើយ ហើយពួកគេបានគិតជាច្រើនដល់ឥស្សរភាពរបស់ឪពុកគេជាងគិតដល់ជីវិតរបស់ខ្លួន មែនហើយ ពួកគេត្រូវបានបង្រៀនដោយម្ដាយរបស់គេថា បើសិនជាពួកគេពុំសង្ស័យទេ នោះព្រះទ្រង់នឹងដោះលែងពួកគេឱ្យរួច” (អាលម៉ា 56:47)។

“ឥឡូវនេះ នេះគឺជាសេចក្ដីជំនឿនៃពួកអ្នកទាំងនេះដែលខ្ញុំបាននិយាយមកនេះ ពួកគេនៅក្មេង ហើយគំនិតគេរឹងប៉ឹង ហើយពួកគេដាក់ទីទុកចិត្តរបស់គេទៅលើព្រះរហូត” (អាលម៉ា 57:27)។

នៅក្នុងបទគម្ពីរទាំងនេះ យើងបានរកឃើញនូវបទដ្ឋានមួយដែលគរកើតមាននៅក្នុងគេហដ្ឋាន និងនៅក្នុងសាសនាចក្រ។ ការបង្រៀនរបស់យើងគួរតែផ្ដោតទៅលើសេចក្ដីជំនឿរបស់យើង និងផ្ដោតជាដំបូង ហើយសំខាន់បំផុតទៅលើការបណ្ដុះសេចក្ដីជំនឿចំពោះព្រះនៅក្នុងជំនាន់កំពុងពេញវ័យនេះ។ យើងត្រូវប្រកាសពីតំរូវការដ៏ចាំបាច់ ដើម្បីគោរពតាម ព្រះបញ្ញត្តិនៃព្រះ និងដើម្បីដើរដោយស្មោះត្រង់នៅចំពោះទ្រង់ក្នុងភាពម៉ឺងម៉ាត់ ឬជាពាក្យម្យ៉ាងទៀតថាដោយគារវភាព។ យើងម្នាក់ៗត្រូវជឿថា ការបំរើ និងការលះបង់សំរាប់សុខុមាលភាព និងសុភមង្គលរបស់មនុស្សដទៃ គឺមានភាពធំធេងជាងការធ្វើឱ្យភាពស្រួល និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ក្លាយជារឿងដ៏សំខាន់បំផុតនោះ។

ការណ៍នេះតំរូវឱ្យមានលើសពីនិយាយម្ដងម្កាលដែលទាក់ទងទៅនឹងគោលការណ៍នៃដំណឹងល្អដ៏ជាក់លាក់ណាមួយទៅទៀត។ វាត្រូវមានការបង្រៀន *ជាទៀងទាត់* ភាគច្រើនតាមរយៈគំរូ។ ប្រធាន ហិនរី ប៊ី អាវរិង បានលើកឡើងពីក្ដីស្រមៃដែលយើងចង់បានថា: “ដំណឹងល្អដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវតែចាក់ចូលទៅក្នុងដួងចិត្ត [របស់កូនចៅយើង] ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។ ការមានសក្ខីភាពខាងវិញ្ញាណអំពីសេចក្ដីពិត ហើយក្រោយមកចង់ធ្វើរឿងល្អៗ នោះគឺពុំគ្រប់គ្រាន់សំរាប់ពួកគេនោះទេ។ ហើយក្ដីសង្ឃឹមចំពោះការលាងសំអាត និងភាពរឹងមាំនាពេលអនាគត គឺពុំគ្រប់គ្រាន់សំរាប់ពួកគេឡើយ។ គោលបំណងសំខាន់របស់យើង គឺត្រូវធ្វើឱ្យពួកគេប្រែក្លាយទៅជាអ្នកផ្លាស់ប្រែចិត្តជឿដ៏ពិតទៅនឹងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ខណៈដែលពួកគេរស់នៅជាមួយយើង។ បន្ទាប់មក ពួកគេនឹងទទួលបានកម្លាំងដោយសារពួកគេជាអ្វីនោះ ពុំមែនអ្វីដែលពួកគេដឹងប៉ុណ្ណោះនោះទេ។ ពួកគេនឹងក្លាយជាសិស្សនៃព្រះគ្រីស្ទ”។6

ខ្ញុំធ្លាប់ស្ដាប់ឮឪពុកម្ដាយមួយចំនួនលើកឡើងថា ពួកគេមិនចង់បង្រៀនដំណឹងល្អដល់កូនចៅរបស់ខ្លួននោះទេ ប៉ុន្តែផ្ទុយទៅវិញពួកគេចង់ឱ្យកូនចៅរបស់ខ្លួនសំរេចចិត្តដោយខ្លួនឯងអំពីអ្វីដែលពួកនឹងជឿ ហើយធ្វើតាមនោះ។ ពួកគេគិតថា ការធ្វើបែបនេះនោះពួកគេនឹងអនុញ្ញាតឱ្យកូនចៅអនុវត្តនូវសិទ្ធិជ្រើសរើសរបស់ខ្លួន។ ពួកគេបានភ្លេចថា ការប្រើសិទ្ធិជ្រើសរើសដោយឈ្លាសវៃតំរូវឱ្យមានចំណេះដឹងនៃសេចក្ដីពិតអំពីរឿងទាំងឡាយ (សូមមើល គ. និង ស. 93:24) បើគ្មានចំណេះដឹងនោះទេ យុវវ័យទាំងឡាយនឹងមានការពិបាកនៅក្នុងការយល់ដឹង និងការវាយតម្លៃចំពោះភាពខុសប្លែកគ្នាដែលកើតឡើងចំពោះមុខរបស់ពួកគេខ្លាំងណាស់។ ឪពុកម្ដាយទាំងឡាយគួរតែពិចារណាពីរបៀបដែលមាសត្រូវ បានខិតចូលមកជិតកូនចៅរបស់ខ្លួន។ វា និងពួកអ្នកដើរតាមវាពុំមែនកំពុងតែលើកដំកើងចំពោះការបើកគំនិតទូលំទូលាយនោះទេ ប៉ុន្តែជាការគាំទ្រដ៏ខ្លាំងក្លាចំពោះអំពើបាប និងភាព-អាត្មានិយម ដោយប្រើវិធីផ្សេងៗគ្នាដើម្បី ធ្វើឱ្យសារលិខិតរបស់វា រីកសាយ។

ការស្វែងរកធ្វើជាមនុស្សអព្យាក្រិត្យចំពោះដំណឹងល្អ តាមការពិត គឺជាការបដិសេធពីវត្តមាននៃព្រះ និងសិទ្ធិអំណាចរបស់ ទ្រង់។ បើយើងចង់ឱ្យកូនចៅរបស់យើងមើលឃើញពីការជ្រើសរើសនៅក្នុងជីវិតដ៏ពិតប្រាកដ និងមានលទ្ធភាពគិតដោយខ្លួនឯង នោះយើងត្រូវទទួលស្គាល់ទ្រង់ និងវត្តមានរបស់ទ្រង់។ ពួកគេមិនចាំបាច់ត្រូវរៀនសូត្រមកពីបទពិសោធន៍ ដ៏សោកសៅថា "សេចក្តី-ទុច្ចរិតពុំដែលជាសុភមង្គលឡើយ" (អាលម៉ា 41:10)។

ខ្ញុំអាចចែកចាយនឹងអ្នករាល់គ្នាពីគំរូដ៏សាមញ្ញមួយនៅក្នុងជីវិតរបស់ខ្ញុំផ្ទាល់ស្តីអំពីអ្វីដែលឪពុកម្តាយអាចធ្វើបាន។ នៅពេលខ្ញុំអាយុប្រហែលជាប្រាំឆ្នាំ ឬប្រាំមួយឆ្នាំ ខ្ញុំបានរស់នៅទល់មុខនឹងហាងលក់ឥវ៉ាន់តូចមួយ។ នាថ្ងៃមួយ មានក្មេងប្រុសពីរនាក់ផ្សេងទៀតបានបបួលខ្ញុំឱ្យទៅហាងនោះជាមួយពួកគេ។ នៅពេលយើងឈរសម្លឹងមើលដោយ ចង់បានស្ករគ្រាប់ដែលគេដាក់លក់នៅទីនោះ នោះក្មេងប្រុសដែលមានអាយុច្រើនជាងគេ បានលូកដៃយកស្ករគ្រាប់ ហើយដាក់នៅក្នុងហោប៉ៅរបស់ខ្លួន។ គាត់បានជំរុញឱ្យក្មេងប្រុសម្នាក់ទៀត ហើយនឹងរូបខ្ញុំធ្វើដូចគ្នានេះដែរ ហើយបន្ទាប់ ពីរាងស្ទាក់ស្ទើរចិត្តបន្តិច នោះយើងក៏បានសំរេចចិត្តធ្វើដូច្នោះ។ បន្ទាប់មក យើងដើរចេញពីហាងនោះ យ៉ាងលឿន ហើយរត់បែកផ្លូវគ្នា។ ខ្ញុំបានរកឃើញកន្លែងលាក់ខ្លួនមួយនៅក្នុងផ្ទះ ហើយបានហែកស្បោងស្ករគ្រាប់នោះ។ ម្តាយរបស់ខ្ញុំបាន រកខ្ញុំឃើញ ហើយដោយឃើញមើលស្នាមស្ករសុកូឡាប្រឡាក់នៅលើមុខរបស់ខ្ញុំ នោះគាត់ក៏បាននាំខ្ញុំត្រឡប់ទៅហាង លក់ឥវ៉ាន់នោះវិញ។ នៅពេលយើងបានដើរឆ្លងផ្លូវ នោះខ្ញុំបានគិតថា ខ្ញុំនឹងត្រូវគេចាប់ដាក់គុកជាមិនខានឡើយ។ ខ្ញុំបានសុំទោសដល់ម្ចាស់ទាំងទឹកភ្នែក និងដោយក្តីរាបសា ហើយបានយកប្រាក់ដប់សេន ដែលអ្នកម្តាយខ្ញុំឱ្យខ្ចី (ដែលខ្ញុំត្រូវធ្វើ ការសងវិញនៅពេលក្រោយនោះ) ដើម្បីសងថ្លៃស្ករគ្រាប់នោះ។ សេចក្តីស្រឡាញ់របស់អ្នកម្តាយខ្ញុំ និងការលត់ដំរបស់ គាត់ បានបញ្ចប់នូវភាពខុសឆ្គងក្នុងជីវិតរបស់ខ្ញុំយ៉ាងឆាប់រហ័ស។

យើងទាំងអស់គ្នាសុទ្ធតែធ្លាប់ជកពិសោធន៍នឹងការល្បួងទាំងឡាយ។ ដូចគ្នានឹងព្រះអង្គសង្គ្រោះផងដែរ ប៉ុន្តែទ្រង់ "មិន បានរវីរវល់នឹងសេចក្តីទាំងនោះឡើយ" (គ. និង ស. 20:22)។ ស្រដៀងគ្នានេះដែរ យើងមិនត្រូវងាយចុះចាញ់ដោយ សារតែមានការល្បួងនៅពីមុខយើងនោះទេ។ មិត្តស្រីម្នាក់ដែលមិនជឿលើសាសនាបានសួរយុវនារីម្នាក់ ដែលបានតាំងចិត្តដើម្បីរស់នៅតាមច្បាប់ព្រហ្មចារីភាព តើវាអាចទៅរួចដោយរបៀបណា ដែលនាងមិនដែល "រួមដំណេកនឹងនរណាម្នាក់" នោះ។ មិត្តនាងបានសួរថា "តើឯងមិនចង់ប្រព្រឹត្តវាទេឬអី?" យុវនារីរូបនោះបានគិតថា "សំណួរនោះបានធ្វើឱ្យខ្ញុំស្រងាកចិត្ត ពីព្រោះវាលើកឡើងមិនចំចំណុច...គ្រាន់តែការចង់ប្រព្រឹត្តនោះ គឺមិនមែនជាគោលការណ៍ណែនាំទៅរកឥរិយាបថដ៏ត្រឹមត្រូវឡើយ"។[7]

នៅក្នុងករណីមួយចំនួន ការល្បួងអាចមានកម្លាំងនៃការញៀន ឬសក្តានុពលភាពនៃការញៀនបន្ថែមទៀត។ ខ្ញុំមានអំណរគុណដែលមានមនុស្សកាន់តែច្រើន ដែលសាសនាចក្រអាចផ្តល់ជាជំនួយ ផ្នែកព្យាបាលគ្រប់ប្រភេទ ដើម្បីជួយពួកគេ ឱ្យជៀសវាង ឬប្រឈមមុខនឹងការញៀន។ ទោះជាយ៉ាងនេះក៏ដោយ ខណៈដែលវិធីព្យាបាលអាចជួយ ដល់ឆន្ទៈរបស់បុគ្គលម្នាក់ ក៏វាមិនអាចមកជំនួសឆន្ទៈរបស់បុគ្គលនោះបានដែរ។ ជានិច្ចតទៅ ការអនុវត្តន៏ការលត់ដំខ្លួនត្រូវមាន---គឺការលត់ដំខ្លួនផ្នែក សីលធម៌ដែលមាននៅក្នុងសេចក្តីជំនឿលើព្រះជាព្រះវរបិតា និងព្រះរាជបុត្រា និងអ្វីដែលទ្រង់អាចធ្វើជាមួយយើងតាមរយៈព្រះគុណដែល

ធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពេត្រុសបានលើកឡើងថា "ព្រះអម្ចាស់ទ្រង់ចេះប្រោសមនុស្សដែលគោរពប្រតិបត្តិដល់ទ្រង់ឱ្យរួចផុតពីការល្បួង" (ពេត្រុសទី 2 2:9) ។

យើងមិនអាចសន្មត់បានថា អនាគតនឹងស្រដៀងគ្នាទៅនឹងអតីតកាល---ហើយថារឿង និងលំនាំទាំងឡាយដែលយើងបានពឹងផ្អែកទាំងផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គមនឹងស្ថិតនៅក្នុងសភាពដដែលនោះបានឡើយ ។ បើយើងចិញ្ចឹម បីបាច់នូវការលត់ដំខ្លួនផ្នែកសីលធម៌របស់យើង នោះវាប្រហែលជានឹងមានឥទ្ធិពលដ៏ល្អមួយ ហើយបំផុសគំនិតអ្នកដទៃឱ្យ ស្វែងរកគុណតម្លៃដូចគ្នានេះផងដែរ ។ ដូច្នេះហើយ យើងអាចមានផលប៉ះពាល់មួយសំរាប់និន្នាការ និងព្រឹត្តិការណ៍នា ពេលអនាគត ។ នៅក្នុងករិតដ៏តូចបំផុតមួយ ការលត់ដំខ្លួនផ្នែកសីលធម៌នឹងក្លាយទៅជាជំនួយដ៏ធំសំរាប់យើង នៅពេលយើងប្រឈមនឹងសម្ពាធ និងឧបសគ្គទាំងឡាយ ដែលអាចកើតឡើងនៅក្នុងសង្គមដ៏អាក្រក់មួយ ។

យើងបានស្តាប់ឮនូវសារលិខិតដែលមានការគិតគូរ និងការបំផុសគំនិតនៅក្នុងសន្និសីទនេះ ហើយបន្តិចទៀតនេះប្រធាន ថូម៉ាស អេស ម៉នសុន នឹងលើកឡើងនូវពាក្យទូន្មានមួយចំនួន ជាកិច្ចបញ្ចប់កម្មវិធី ។ នៅពេលយើងពិចារណាប្រកប ដោយការអធិស្ឋានចំពោះអ្វីដែលយើងបានរៀន និងបានរៀនឡើងវិញម្តងទៀត នោះខ្ញុំជឿថា ព្រះវិញ្ញាណនឹងបញ្ចេញ ពន្លឺបន្ថែមទៀតទៅលើរឿងទាំងឡាយណាដែលមានសារៈសំខាន់ដ៏ជាក់លាក់សំរាប់យើងម្នាក់ៗ ។ យើងនឹងបានរឹងមាំនៅ ក្នុងការលត់ដំខ្លួនផ្នែកសីលធម៌ដែលចាំបាច់ ដើម្បីដើរដោយស្មោះត្រង់ចំពោះព្រះអម្ចាស់ ហើយរួបរួមជាមួយនឹងទ្រង់ និងព្រះវរបិតា ។

បងប្អូនប្រុសស្រីទាំងឡាយ ខ្ញុំសូមឈរជាមួយនឹងបងប្អូនប្រុសរបស់ខ្ញុំ ព្រមជាមួយនឹងអ្នករាល់គ្នា ក្នុងនាមជាសាក្សី មួយរូបថាព្រះគឺជាព្រះវរបិតារបស់យើង ហើយថា ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវ គឺជាព្រះប្រោសលោះរបស់យើង ។ ក្រិត្យវិន័យរបស់ទ្រង់ គឺគ្មានការផ្លាស់ប្តូរនោះទេ ។ សេចក្តីពិតរបស់ទ្រង់នឹងមានជារៀងរហូត ។ ហើយសេចក្តី ស្រឡាញ់របស់ទ្រង់ គឺគ្មានទីបញ្ចប់ឡើយ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. James E. Faust, *Stories From My Life* [ឆ្នាំ 2001] ទំព័រ 2--3 ។

2. Walter Williams, "Laws Are a Poor Substitute for Common Decency, Moral Values," *Deseret News* ថ្ងៃទី 29 ខែ មេសា ឆ្នាំ 2009 ទំព័រ A15 ។

3. ពេលនិយាយកាលពីប៉ុន្មានឆ្នាំមុន ទៅកាន់សមាជិកនៃពួកអ្នកជំនាញផ្នែកច្បាប់ ប្រធាន ជែមស៍ អ៊ី ហ្វោស្ដ បានដាស់តឿនថា "នៅក្នុងការធ្វើយុត្តិកម្មចំពោះអ្វីដែលយើងធ្វើជាលក្ខណៈផ្ទាល់ខ្លួន និងលក្ខណៈជំនាញដោយផ្អែកទៅលើអ្វីដែល 'ស្របច្បាប់' ជាជាងអ្វីដែល 'ត្រឹមត្រូវ' គឺមានហានិភ័យដ៏ធំ ។ ដោយការធ្វើបែបនេះ យើងបានដាក់ដួងព្រលឹងរបស់យើងនៅក្នុងហានិភ័យ ។ ទស្សនៈដែលលើកឡើងថា អ្វីដែលស្របច្បាប់ក៏ជារឿងត្រឹមត្រូវដែរ នឹងដកយកនូវអ្វីដែលខ្ពស់ ហើយល្អបំផុតចេញពីចរិតលក្ខណៈរបស់យើង ។ ការប្រព្រឹត្តស្របច្បាប់ គឺស្ថិតនៅក្រោមយ៉ាងឆ្ងាយពីបទដ្ឋាននៃសង្គមស៊ីវិល ហើយកាន់តែនៅក្រោមការបង្រៀនរបស់ព្រះគ្រីស្ទយ៉ាងឆ្ងាយ ។ បើអ្នករាល់គ្នាទទួលយកអ្វីដែលស្របច្បាប់ធ្វើជាបទដ្ឋានសំរាប់ការប្រព្រឹត្តផ្ទាល់ខ្លួន និងសំរាប់អាជីព

នោះអ្នកនឹងបដិសេធខ្លួនឯងចេញពីអ្វីដែលជាភាពថ្លៃថ្នូរដ៏ពិតប្រាកដនៅក្នុងកិត្តិយស និងគុណតម្លៃផ្ទាល់ខ្លួនរបស់អ្នកហើយ" ( ប្រធាន ជែមស៍ អ៊ី ហ្វោស្ត "Be Healers" *Clark Memorandum*, J. Reuben Clark Law School, Brigham Young University និទាឃរដូវ ឆ្នាំ 2003 ទំព័រ 3) ។

4. "Bishop Fulton John Sheen Makes a Wartime Plea," ដកស្រង់ចេញពី *Lend Me Your Ears, Great Speeches in History* រៀបរៀងដោយ William Safire [ឆ្នាំ 1997] ទំព័រ 478 ។

5. មានពេលមួយ វិចារណកថារបស់ពួកអ្នកនិពន្ធសំរាប់សារព័ត៌មាន *The Wall Street Journal* បានលើកឡើងថា "អំពើបាបពុំមែនជាអ្វីមួយដែលមនុស្សជាច្រើន រួមទាំងព្រះវិហារភាគច្រើនដែរ បានចំណាយពេលជាច្រើន ដោយលើកឡើង ឬមានការព្រួយបារម្ភ នៅក្នុងអំឡុងពេលនៃបដិវត្ត[ផ្លូវភេទ] នោះឡើយ ។ ប៉ុន្តែ យើងសូមនិយាយអំពើបាប តាមរបៀបនេះ វិញថា : វាបានផ្តល់ឱ្យយ៉ាងហោចណាស់នូវអារម្មណ៍នៃការបញ្ចូលមួយសំរាប់សិរិយាបទផ្ទាល់ខ្លួន។ នៅពេលការបញ្ចូល នោះត្រូវបានបំបែកចេញជាបំណែកតូចៗ នោះទោសកំហុសពុំមែនជារឿងតែម្យ៉ាងដែលមិនមានការព្រមទទួលឡើយ ប៉ុន្តែយើងក៏បាត់បង់នូវបទដ្ឋាននៃការទទួលខុសត្រូវផ្ទាល់ខ្លួនផងដែរ...។ សហរដ្ឋអាមេរិកមានបញ្ហាថ្នាំញៀន បញ្ហារួមភេទតាមវិទ្យាល័យ បញ្ហាសុខុមាលភាព បញ្ហាជម្ងឺអេដស៍ និងបញ្ហាចាប់រំលោភ។ ចំពោះបញ្ហានេះ គឺគ្មានអ្វីមួយនឹងត្រូវបានលុបបំបាត់ចោលឡើយ រហូតដល់មនុស្សដែលមានតួនាទីទទួលខុសត្រូវមានឆន្ទៈចេញមក ហើយពន្យល់ នៅក្នុងពាក្យសីលធម៌បើកទូលាយ ថារឿងមួយចំនួនដែលមនុស្សគ្រប់គ្នាកំពុងធ្វើសព្វថ្ងៃនេះ គឺជារឿងខុសឆ្គង" ("The Joy of What?" *The Wall Street Journal* ថ្ងៃទី 12 ខែ ធ្នូ ឆ្នាំ 1991 ទំព័រ A14) ។

6. Henry B. Eyring, in Shaun D. Stahle "Inspiring Students to Stand Strong amid Torrent of Temptation" *Church News* ថ្ងៃទី 18 ខែ សីហា ឆ្នាំ 2001 ទំព័រ 5 ។

7. Sarah E. Hinlicky "Subversive Virginity" *First Things* ខែ តុលា ឆ្នាំ 1998 ទំព័រ 14 ។